January 23, 2019

# EU និងកម្ពុជាពិភាក្សាពីពន្ធអនុគ្រោះ EBA




*រូបឯកសារ៖ លោកស្រី សេស៊ីលៀ ម៉ាលស្ត្រុម ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប ថ្លែងក្នុងសន្និសីទកាសែតមួយ ក្រោយពីអាមេរិកប្រកាសយកពន្ធលើដែកថែបនិងអាលុយមីញ៉ូម នៅទីស្នាក់ការសហភាពអឺរ៉ុបក្នុងទីក្រុង ប្រ៊ុចសែល កាលពីថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៨។*
(AP/Virginia Mayo)

*ម៉ែន គឹមសេង* | VOA Khmer, 23 *មករា* 2019

*វ៉ាស៊ីនតោន — តំណាងសហភាពអឺរ៉ុបបានជួបពិភាក្សាជាមួយនឹងមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃច័ន្ទពីលទ្ធភាពដកហូត:អនុគ្រោះពន្ធ បើសិនជាស្ថានភាពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យមិនល្អប្រសើរឡើងវិញទេ។*

*លោកស្រី សេស៊ីលៀ ម៉ាលស្ត្រុម* (Cecilia Malstrom) *ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុបបានបញ្ជាក់តាមសារធ្វីតធើ* (Twitter) *ពីជំនួបជាមួយនឹងលោក ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេសកម្ពុជានៅក្នុងទីក្រុង ប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក ថា៖*

«យើងបានពិភាក្សាពីកិច្ចព្រមព្រៀងEBA និងលទ្ធភាពដកហូតឋានៈអនុគ្រោះពន្ធ។ ដោយបានបញ្ជាក់ពីការព្រួយបារម្ភរបស់យើងពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។ សហភាពអឺរ៉ុបនៅបន្តច្រកចរចាបើកចំហដដែល»។

រីឯលោក ប្រាក់ សុខុន ក៏បានបញ្ជាក់តាមទំព័រហ្វេសប៊ុករបស់លោកដែរថា លោកបានជួបពិភាក្សាការងារជាមួយលោកស្រី សេស៊ីលីលៀ ម៉ាលស្ត្រុម ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប នៅក្រៅកិច្ចប្រជុំលើកទី២២ រដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប នៅទីក្រុង ប្រ៊ុចសែល ដែរ។ ប៉ុន្តែលោកមិនបានបញ្ជាក់ពីជំហររបស់កម្ពុជាទេ។

សហភាពអឺរ៉ុបបានចាប់ផ្ដើមដំណើរការពិនិត្យមើលលទ្ធភាពដកឋានៈអនុគ្រោះពន្ធ«គ្រប់មុខទំនិញលើកលែងសព្វាវុធ»(EBA) តាំងពីខែតុលាមកដោយសារតែការដើរថយក្រោយនៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សនៅកម្ពុជាក្រោយពីរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើទុក្ខបុកម្នេញអ្នកនយោបាយអតីតគណបក្សប្រឆាំង បង្រ្កាបលើបណ្ដាញព័ត៌មានឯករាជ្យ និងអង្គការសង្គមស៊ីវិលនៅមុនពេលបោះឆ្នោតជាតិខែកក្កដា ឆ្នាំ ២០១៨។

សហភាពអឺរ៉ុបគឺជាទីផ្សារនាំចេញដ៏ធំជាងគេបំផុតរបស់កម្ពុជាហើយ ការអនុគ្រោះពន្ធធ្វើឱ្យកម្ពុជាចំណេញប្រាក់ជិត៧០០លានដុល្លារក្នុងមួយឆ្នាំៗ។ ប៉ុន្តែកាលពីថ្ងៃសុក្រសប្ដាហ៍មុនសហភាពអឺរ៉ុបបានចាប់ផ្ដើមយកពន្ធអង្ករកម្ពុជារយៈពេល៣ឆ្នាំដោយសារតែបរិមាណនាំចូលមានការកើនឡើងច្រើន ដែលការណ៍នេះធ្វើឱ្យកម្ពុជាត្រូវបង់ពន្ធចំនួន៩០លានដុល្លារក្នុងមួយឆ្នាំៗ៕